County of Los Angeles
DEPARTMENT OF
PUBLIC SOCIAL SERVICES

# សេចក្តីជូនដំណឹងព័ត៌មានអំពីសិទ្ធិនៃពលរដ្ឋ
# (CIVIL RIGHTS INFORMATION NOTICE)

## តើអ្វីទៅជាសិទ្ធិនៃពលរដ្ឋ?

សិទ្ធិនៃពលរដ្ឋគឺជាច្បាប់ ដែលការពារ បុគ្គលគ្រប់រូបពីការរើសអើងលើពូជសាសន៍ ភេទ ។ល។ ច្បាប់សិទ្ធិនៃពលរដ្ឋដែលបានចងក្រងនៅឆ្នាំ 1964 វគ្គលេខ 504 នៅក្នុងច្បាប់ស្តីអំពីរូបបដិទាននៃឆ្នាំ 1973 ច្បាប់ការពារជនពិការភាពអាមេរិកាំងនៃឆ្នាំ 1990 និង បទបញ្ញាផ្សេងៗទៀត របស់សហព័ន្ធ និងរដ្ឋបានចែងថា ការរើសអើង គឺជាអំពើខុសច្បាប់នៅក្នុងកម្មវិធីនានាដែលទទួលជំនួយផ្នែកហិរញ្ញវត្ថុពីសហព័ន្ធ និងរដ្ឋ។

## តើច្បាប់នេះការពារអ្នកណាខ្លះ?

បើសិនជាអ្នកដាក់ពាក្យស្នើសុំឬទទួលជំនួយជាសាច់ប្រាក់ ជំនួយ Medi-Cal ជំនួយខលហ្វ្រេស៍ (CalFresh) ឬ ជំនួយបំរើកិច្ចការសង្គមនៅក្នុងខោនធី Los Angeles អ្នកត្រូវបានគេការពារតាមផ្លូវច្បាប់ ប្រឆាំងនឹងការរើសអើងទាក់ទងនឹងអត្ថប្រយោជន៍ទាំងនេះ ហើយអ្នកមានសិទ្ធិដាក់លាក់។

អ្នកមានសិទ្ធិទទួលការបំរើដូចៗគ្នា ការពិចារណា និងការរាប់អានដូចៗគ្នា ដែលត្រូវបានគេផ្តល់ឲ្យទៅ អ្នកដាក់ពាក្យស្នើសុំ ឬអ្នកចូលរួមដទៃទៀតទាំងអស់ ដោយមិនគិតពី៖

*ពូជសាសន៍ ពណ៌សម្បុរ ពូជពង្ស សញ្ជាតិដើម (រាប់បញ្ចូលទាំងភាសា) ការកំណត់អត្តសញ្ញាណក្រុមជនជាតិ អាយុ ពិការភាពផ្លូវកាយ ឬផ្លូវចិត្ត ស្ថានភាពសុខភាព សាសនា ភេទ យេនឌ័រ អត្តសញ្ញាណយេនឌ័រ ឬទំនោរយេនឌ័រ ទំនោរផ្លូវភេទ ភាពមានគ្រួសារឬនៅលីវ ភាពជាដៃគូក្នុងគ្រួសារ ការចូលជាគណៈបក្សនយោបាយ សញ្ជាតិ ស្ថានភាពអន្តោប្រវេសន៍ ព័ត៌មានខាងហ្សែន និងសកម្មភាពនៃការវាយបកមកវិញ។*

អ្នកមានសិទ្ធិ៖

- ទទួលបានសេវាបកប្រែដោយឥតគិតថ្លៃ ជាភាសាណាមួយនៅពេលដាក់ពាក្យស្នើសុំ អត្ថប្រយោជន៍ ឬបន្តទទួលបានអត្ថប្រយោជន៍។
- ទូរស័ព្ទទៅមជ្ឈមណ្ឌលសេវាកម្មអតិថិជននៃ DPSS លេខ 866-613-3777 និងសុំឲ្យសេចក្តីជូនដំណឹងពីខោនធីដែលអ្នកបានទទួលជាភាសាអង់គ្លេស ឱ្យគេអាន បកប្រែ និង ពន្យល់ជូនអ្នកជាភាសាណាមួយនិង
- ទទួលបានការសម្របសម្រួលដ៏សមរម្យ ប្រសិនបើអ្នកមានពិការភាពខាងផ្លូវកាយ ឬ ផ្លូវសតិអារម្មណ៍ ដើម្បីជួយអ្នកក្នុងការទទួលបានព័ត៌មាន និង ចូលរួមនៅក្នុងកម្មវិធី និង សេវាកម្មរបស់ DPSS ។

## របៀបដាក់ពាក្យស្នើសុំសំណុំរឿងតវ៉ា

ប្រសិនបើអ្នកជឿថា អ្នកត្រូវបានគេរើសអើងដោយសារពូជសាសន៍ ពណ៌សម្បុរ ពូជពង្ស ដើមកំណើតជាតិ (រួមទាំងភាសា) ការកំណត់ក្រុមជនជាតិភាគតិច អាយុ ពិការភាពខាងផ្លូវកាយ ឬផ្លូវចិត្ត ស្ថានភាពសុខភាព សាសនា ភេទ យេនឌ័រ អត្តសញ្ញាណយេនឌ័រ ឬទំនោរយេនឌ័រ ទំនោរផ្លូវភេទ ភាពមានគ្រួសារឬនៅលីវ ភាពជាដៃគូក្នុងគ្រួសារ ការចូលជាគណៈបក្សនយោបាយ សញ្ជាតិ ស្ថានភាពអន្តោប្រវេសន៍ និង/ឬ ព័ត៌មានខាងហ្សែន ឬអ្នកធ្លាប់មានការវាយបកមកវិញដោយបុគ្គលិករបស់ DPSS ឬអ្នកម៉ៅការ នៅពេលនោះអ្នកអាចធ្វើសកម្មភាពមួយ ឬទាំងអស់ដូចខាងក្រោម៖

អ្នកអាចស្នើសុំនិយាយជាមួយ អ្នកទំនាក់ទំនងផ្នែកសិទ្ធិនៃពលរដ្ឋរបស់ក្រសួងសង្គមកិច្ចសាធារណៈ (DPSS) ។ ពួកគេអាចជួយអ្នកដាក់ពាក្យបណ្តឹងផ្នែកសិទ្ធិនៃពលរដ្ឋ ដោយការផ្តល់នូវសំណៅ PA 607 "សេចក្តីតវ៉ាអំពីការប្រកាន់រើសអើង ពូជសាសន៍ ភេទ ។ល។" និង ជួយអ្នកបំពេញសំណៅនេះអោយបានចប់សព្វគ្រប់។

អ្នកក៏អាចទាក់ទងក្រសួងសង្គមកិច្ចសាធារណៈ (DPSS) នៃខោនធីឡូសអិនយឺឡេស ទីភ្នាក់ងាររដ្ឋ និងសហព័ន្ធដោយផ្ទាល់ ដោយប្រើព័ត៌មានទំនាក់ទំនង ដែលបានរាយនៅផ្នែកម្ខាងទៀតនៃសេចក្តីជូនដំណឹងនេះ។

អ្នកអាចស្នើសុំការស៊ើបអង្កេតពី អង្គភាពអនុលោមតាមច្បាប់ផ្នែកសិទ្ធិនៃពលរដ្ឋរបស់ DPSS ដោយផ្ទាល់មាត់ ឬសរសេរជាលាយលក្ខណ៍អក្សរតាមសំបុត្រ ដោយទាក់ទងទៅអ្នកសម្របសម្រួលផ្នែកសិទ្ធិនៃពលរដ្ឋ។ អ្នកអាចសរសេរនូវសេចក្តីថ្លែងការណ៍ផ្ទាល់ខ្លួនរបស់អ្នក ឬ ប្រើសំណៅ PA 607 ដើម្បីចងក្រងឯកសារលើពាក្យបណ្តឹងរបស់អ្នក។ សំណៅ PA 607 គឺមានផ្តល់ជូនសំរាប់បុគ្គលណាម្នាក់ឬតំណាងអង្គការនៅក្នុងសហគមន៍ដែលស្នើសុំសំណៅនេះ។ វាក៏មានផ្តល់ជូនផងដែរ នៅលើបណ្តាញ dpss.lacounty.gov.

អង្គភាពអនុលោមតាមច្បាប់ផ្នែកសិទ្ធិនៃពលរដ្ឋ នឹងទាក់ទងទៅអ្នកសម្រាប់ព័ត៌មានបន្ថែម ប្រសិនបើចាំបាច់ និងជូនដំណឹងដល់អ្នកពីការរកឃើញនៅក្នុងការស៊ើបអង្កេតដោយសរសេរជាលាយលក្ខណ៍អក្សរ។ ប្រសិនបើអ្នកមិនយល់ស្របនឹងការរកឃើញរបស់ខោនធី (រួមទាំង ប្រសិនបើខោនធីមិនបានស៊ើបអង្កេតនូវ ពាក្យបណ្តឹងរបស់អ្នក) អ្នកអាចប្តឹងតវ៉ាទៅក្រសួងសង្គមកិច្ចសាធារណៈនៃរដ្ឋកាលីហ្វ័រនីញ៉ាក្នុងរយៈពេល 30 ថ្ងៃ ឬប្រសិនបើ វាពាក់ព័ន្ធនឹងកម្មវិធី CalFresh អ្នកអាចប្តឹងតវ៉ាទៅក្រសួងកសិកម្មនៃសហរដ្ឋអាមេរិកក្នុងរយៈពេល 90 ថ្ងៃ ។

**ពាក្យបណ្តឹងរបស់អ្នកត្រូវតែដាក់ក្នុងរយៈពេល 180 ថ្ងៃ គិតចាប់ពីថ្ងៃដែលអ្នកជឿថាអ្នកត្រូវបានគេរើសអើង ។**

ប្រសិនបើពាក្យបណ្តឹងអំពីការរើសអើងនេះ ប៉ះពាល់ដល់អត្ថប្រយោជន៍ និងសេវាកម្មរបស់អ្នក អ្នកអាចស្នើសុំសវនាការរដ្ឋ។ ការស៊ើបអង្កេតអំពីការរើសអើងមិនអាចផ្លាស់ប្តូរអត្ថប្រយោជន៍ឬសេវាកម្មរបស់អ្នកបានទេ។ មានតែសវនាការរបស់រដ្ឋប៉ុណ្ណោះ ដែលអាចធ្វើដូច្នោះបាន។ DPSS មិនអាចវាយបកទៅអ្នកវិញទេ ប្រសិនបើអ្នកស្នើសុំសវនាការ ឬ ដាក់ពាក្យបណ្តឹងអំពីការរើសអើងពូជសាសន៍ ភេទ ។ល។

អ្នកអាចដាក់ពាក្យបណ្តឹងអំពីការរើសអើងរបស់អ្នកជាមួយទីភ្នាក់ងារខោនធី រដ្ឋ និងសហព័ន្ធ មួយ ឬទាំងអស់ដែលអាចអនុវត្តន៍បាន ដូចខាងក្រោម៖

### ការិយាល័យខោនធីឡូសអិនយឺឡេស

**(Los Angeles County Office)**

សម្រាប់កម្មវិធីទាំងអស់ដែលបានគ្រប់គ្រងដោយ
Los Angeles County:
Department of Public Social Services
Civil Rights Coordinator
12860 Crossroads Parkway South
City of Industry, CA 91746
(562) 908-8501
DPSSCivilRights@dpss.lacounty.gov

### កម្មវិធីការធានារ៉ាប់រងសុខភាពរដ្ឋកាលីហ្វ័រនីញ៉ា

**(Covered California)**

អ្នកសម្របសម្រួលផ្នែកសិទ្ធិនៃពលរដ្ឋសំរាប់កម្មវិធីការធានារ៉ាប់រងសុខភាពរដ្ឋកាលីហ្វ័រនីញ៉ា
P.O. Box 989725
West Sacramento, CA 95789
(916) 228-8764
CivilRights@covered.ca.gov

### កម្មវិធីថែទាំសុខភាព និងថែទាំធ្មេញរបស់ម៉េឌី-ខាល់

**(Medi-Cal & Medi-Cal Dental Program)**

### ក្រសួងសេវាសុខភាពសាធារណៈ:

**(Department of Public Health Services)**
Office of Civil Rights
P.O. Box 997413, MS0009
Sacramento, CA 95899-7413
(916) 440-7370 or 711 (CA Relay Service)
CivilRights@dhcs.ca.gov

### កម្មវិធីរដ្ឋកាលីហ្វ័រនីញ៉ា (California) ផ្សេងៗទៀត

ក្រសួងសង្គមកិច្ចសាធារណៈនៃរដ្ឋ California
Civil Rights Section
744 P Street, M/S 9-7-041
Sacramento, CA 95814
(866) 741-6241 (លេខឥតគិតថ្លៃ)

crb@dss.ca.gov

### ទីភ្នាក់ងារសហព័ន្ធ

ដើម្បីដាក់ពាក្យបណ្តឹងអំពីការរើសអើងផ្អែកលើពូជសាសន៍ ពណ៌សម្បុរ សញ្ជាតិដើម ពិការភាព អាយុ ឬភេទ (រួមទាំងការមានផ្ទៃពោះ ទំនោរផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រ)៖
U.S. Department of Health and Human Services
Office of Civil Rights
200 Independence Avenue, SW
Suite 5F, HHH Building
Washington, DC 20201

ដាក់ពាក្យបណ្តឹងអនឡាញតាមគេហទំព័រ៖
US Health & Human Services Civil Rights Complaint Portal
(800) 368-1019 (លេខឥត គិត ថ្លៃ)

(800) 537-7697 (ពិការខាងការស្តាប់/ការនិយាយស្តី)

### កម្មវិធីខាល់ហ្វ្រែស (CalFresh)

**ដើម្បីដាក់ពាក្យបណ្តឹងអំពីកម្មវិធី CalFresh ជាមួយទីភ្នាក់ងារសហព័ន្ធ៖**

បំពេញសំណៅ AD-3027, សំណៅដាក់ពាក្យបណ្តឹងអំពីការរើសអើងលើកម្មវិធីរបស់ក្រសួងកសិកម្មនៃសហរដ្ឋអាមេរិក (USDA) ឬ ផ្ញើសំបុត្រដាក់ពាក្យប្តឹង វាជាលាយលក្ខណ៍អក្សរទៅអាស័យដ្ឋាន នេះ

U.S. Department of Agriculture
Office of the Assistant Secretary for Civil Rights
1400 Independence Avenue, SW Mail Stop 9410
Room 1330, South Building
Washington, CA 20250
FNSCIVILRIGHTSCOMPLAINTS@usda.gov

### ការស្នើសុំសវនាការរដ្ឋ

ប្រសិនបើអ្នកមិនយល់ស្របនឹងសកម្មភាព ឬភាពអសកម្មណាមួយដែលបានធ្វើឡើងដោយ DPSS ទាក់ទងទៅនឹងអត្ថប្រយោជន៍ ឬ វាកម្មនានារបស់អ្នក អ្នកអាចស្នើសុំសវនាការរដ្ឋមួយ។

អ្នកត្រូវតែដាក់ពាក្យស្នើសុំសវនាការរដ្ឋ ក្នុងរយៈពេល 90 ថ្ងៃ នៃសកម្មភាពរបស់ខោនធី។ រយៈពេល 90 ថ្ងៃ ត្រូវបានអនុវត្តន៍ ជាអ្នកបានដាក់ពាក្យស្នើសុំសិទ្ធិនៃពលរដ្ឋហើយក៏ដោយ។ កា រង់ចាំការបង់ប្រាក់ផ្ទួយ អាចត្រូវបានទទួល ប្រសិនបើ អ្នកដាក់ពាក្យស្នើសុំសវនាការតវ៉ាបំភ្លឺមួយមុនពេល កាលបរិច្ឆេទចាប់ផ្តើមមានប្រសិទ្ធិភាពចំពោះការសម្រេចចិត្តដែលបានគ្រោងទុក។

អ្នកអាចស្នើសុំសវនាការរដ្ឋសូមបំពេញនៅខាងក្រោយនៃសេចក្តីប្រកាសនូវការសម្រេចចិត្ត (សំបុត្រជូនដំណឹង) ដែលទទួលបានពីការិយាល័យ DPSS ឬដោយការសរសេរជាសំបុត្រ (សូមរក្សាសំបុត្រចម្លង) ហើយសេចក្តីស្នើសុំរបស់អ្នកទៅ៖

- ប្រៃសណីយ៍ ៖
  ផ្នែកសវនាការរដ្ឋ CDSS
  PO Box 944243, MS 21-37
  Sacramento, CA 94244-2430
- ការបង្ហាញខ្លួនដោយផ្ទាល់៖
  បណ្តឹងឧទ្ធរណ៍ និងផ្នែកសវនាការរដ្ឋ
  3833 S. Vermont Ave, 4th Floor
  Los Angeles, CA 90037
- ទូរស័ព្ទ៖
  (800) 743-8525 ឬ (800) 952-8349 (TDD)
- អនឡាញនៅ៖ www.acms.dss.ca.gov
- អ៊ីមែល៖ SHDCSU@DSS.ca.gov

ប្រសិនបើការព្រួយបារម្ភរបស់អ្នក ទាក់ទងនឹងជំនួយទូទៅ អ្នកអាចទាក់ទងទៅក្រសួងសង្គមកិច្ចសាធារណៈ (DPSS) របស់ខោនធីឡូនអិនយឺឡេស ដើម្បីស្នើសុំសវនាការតវ៉ា។

### ការសម្របសម្រួលដ៏សមរម្យ និងសមហេតុផល ៖ ជំនួយពិសេសសម្រាប់មនុស្សដែលមានពិការភាព

មនុស្សទាំងឡាយណាដែលមានពិការភាពផ្នែកផ្លូវកាយ ឬផ្លូវចិត្ត មានសិទ្ធិស្នើសុំការសម្របសម្រួលដ៏សមរម្យ និងសមហេតុផលពី DPSS ដើម្បីជួយពួកគេឲ្យទទួលបាន និង ចូលរួមក្នុងកម្មវិធី និងសេវាកម្ម។ DPSS ត្រូវតែធ្វើការជាមួយអ្នកដើម្បីកំណត់ជំនួយ ដែលអ្នកត្រូវការ។ ប្រសិនបើ DPSS បដិសេធសំណើររបស់អ្នក យើងត្រូវផ្តល់ឲ្យអ្នកនូវសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរ ដោយបញ្ជាក់អំពីមូលហេតុនៃការបដិសេធ។ សេចក្តីជូនដំណឹង ត្រូវតែរាយបញ្ជីអំពីសិទ្ធិស្នើសុំសវនាការតវ៉ារបស់អ្នក។

ព័ត៌មានបន្ថែមអំពីសិទ្ធិនៃពលរដ្ឋ និងសវនាការរដ្ឋគឺមានផ្តល់ជូននៅកន្លែងទទួលភ្ញៀវនៃការិយាល័យខ័ណ្ឌ/តំបន់។ អ្នកអាចសួររក កូនសៀវភៅផ្សព្វផ្សាយរដ្ឋ *សិទ្ធិរបស់អ្នកនៅក្រោម កម្មវិធីជំនួយសាធារណៈនៃរដ្ឋកាលីហ្វ័រនីញ៉ា* (PUB 13) ដែលមាននៅគ្រប់កន្លែងទទួលភ្ញៀវទាំងអស់។